ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩

## សំរេច

**មាត្រា ១** : មន្ត្រីរាជការស៊ីវិល មន្ត្រី តុលាការ មន្ត្រី នគរបាលជាតិ និង កងយោធពលខេមរភូមិន្ទ ដែល បំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ហើយត្រូវបានតែងតាំងជាសមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ និងទីប្រឹក្សាគ្រប់ឋានុក្រមត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌ នៃក្រសួង ស្ថាប័នដើម ។

សហការរៀបចំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង កម្មវិធីកំណែទម្រង់រដ្ឋបាល និង វិមជ្ឈការ (GTZ)-ចម្លងខ្ទឹមសារទាំងស្រុងតាមច្បាប់ដើម

**មាត្រា ២** : មន្ត្រីសាមីត្រូវដាក់ពាក្យសុំតាមឋានុក្រមទៅបំរើការងារនៅក្រៅក្របខ័ណ្ឌដើមនៅក្រសួង ស្ថាប័ន ដែលមន្ត្រីសាមីបំពេញការងារកន្លងមក ក្រោយពីពេលទទួលបានការតែងតាំងមុខតំណែងថ្មីជាផ្លូវការ ។

**មាត្រា ៣** : មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលមានក្របខ័ណ្ឌទាំងអស់ហើយត្រូវបានតែងតាំងក្នុងមុខតំណែងដូចមានចែងក្នុងមាត្រា១ ត្រូវផ្អាកបៀវត្សពីក្រសួង ស្ថាប័នដើម ហើយ ផ្ទេរបៀវត្សទៅក្រសួង ស្ថាប័ន ដែល ត្រូវទៅបំពេញភារកិច្ចក្នុងមុខតំណែង ដោយទទួលបៀវត្សទៅតាមប្រភេទបៀវត្សចុងក្រោយ ព្រម ទាំងទទួលប្រាក់បំណាច់ប្រចាំខែ តា មការកំណត់របស់រាជរដ្ឋាភិបាល ។

**មាត្រា ៤** : មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រី នគរបាលជាតិ និង កងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា១ ខាងលើ ក្នុងរយៈពេល ស្ថិតនៅក្រៅក្របខ័ណ្ឌដើមនេះ ត្រូវបាន គិតអតីតភាពសំរាប់តំឡើងឋានន្តរស័ក្ត ឬថ្នាក់ និងគិតអតីតភាពការងារសំរាប់ទទួលសោធនិវត្តន៍ ។

**មាត្រា ៥** : មន្ត្រីសាមីដូចមានចែងក្នុងមាត្រា១ ខាងលើត្រូវដាក់ពាក្យសុំចូលបំរើការងារក្នុងក្របខ័ណ្ឌដើមវិញ នៅពេលចប់អាណត្តិ ឬនៅពេលលាឈប់ពីមុខតំណែង ។ ក្រសួង ស្ថាប័ន សាមី ត្រូវទទួលអោយចូលបំរើការងារវិញ ដោយរក្សាឋានន្តរស័ក្តិ និងថ្នាក់ដែលក្រសួង ស្ថាប័ននៃក្របខ័ណ្ឌដើមបានបន្តរៀបចំជូន ដូចមានចែងក្នុងមាត្រា៤ ខាងលើ ។

**មាត្រា ៦** : ចំពោះមុខតំណែងជាទីប្រឹក្សា ឬជំនួយការដែលត្រូវបានតែងតាំងបន្ថែមលើមុខតំណែង ក្នុង មុខងារសាធារណៈនោះ មន្ត្រីសាមីពុំចាំបាច់ដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើមឡើយ ។

**មាត្រា ៧** : មន្ត្រីរាជការស៊ីវិល មន្ត្រី តុលាការ មន្ត្រី នគរបាលជាតិ និង កងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា១ ខាងលើដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីបំពេញទំរង់បែបបទអោយស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ ។

**មាត្រា ៨** : មន្ត្រីដែលកាន់មុខតំណែងដូចមានចែងក្នុងមាត្រា ១ ខាងលើ ពេលដល់អាយុចូលនិវត្តន៍ ត្រូវបំពេញបែបបទចូលនិវត្តន៍ជូនទៅក្រសួង ស្ថាប័នដើម ដូច មន្ត្រីដែលកំពុងបំពេញក្នុងមុខងារសាធារណៈដែរ ។ មន្ត្រីសាមីនៅតែបន្តការងារក្នុងមុខតំណែងនយោបាយដដែល ដោយ ត្រូវទទួលប្រាក់សោធននិវត្តន៍តាមគោលការណ៍របស់រដ្ឋ និងទទួលប្រាក់បំណាច់បន្ថែមនៅក្រសួងស្ថាប័ន ដែលមន្ត្រីសាមីបំពេញភារកិច្ចក្នុងមុខតំណែង ។ ករណី នេះ ក្រសួង ស្ថាប័នត្រូវផ្តល់ជូនបន្ថែមនូវប្រាក់កំរៃដូចមន្ត្រីជាប់កិច្ចសន្យា ដោយមានទឹកប្រាក់ស្មើនឹងប្រាក់បៀវត្សចុងក្រោយរបស់មន្ត្រីសាមី ។

**មាត្រា ៩** : មន្ត្រីដែលចូលនិវត្តន៍រួចហើយៗ ត្រូវ បានតែងតាំងក្នុងមុខតំណែងដូចមានចែងក្នុងមាត្រា១ ត្រូវបានទទួលប្រាក់បំណាច់បន្ថែម ព្រមទាំងប្រាក់កំរៃ ដូច ជាមន្ត្រីជាប់កិច្ចសន្យា ដោយមានទឹកប្រាក់ស្មើនឹងបៀវត្សចុងក្រោយរបស់មន្ត្រីសាមី ។

**មាត្រា ១០** : មន្ត្រីដែលពីមុនពុំស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋ ហើយ ត្រូវបានតែងតាំងក្នុងមុខតំណែង ដូច មានចែងក្នុងមាត្រា១ ត្រូវបានទទួលប្រាក់បំណាច់បន្ថែម និងទទួលប្រាក់កំរៃជាមន្ត្រីជាប់កិច្ចសន្យា ដោយមានទឹក

ប្រាក់ដែលកំណត់ដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ១១** : មន្ត្រីដែលបំរើការងារក្នុងខុទ្ទកាល័យរបស់ប្រធានស្ថាប័ន រួម មានៈ ទីប្រឹក្សា ជំនួយ ការ នាយកខុទ្ទកាល័យ នាយខុទ្ទកាល័យ និង មន្ត្រីខុទ្ទកាល័យផ្សេងទៀត ដូច មានចែងក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាននោះ ត្រូវ ដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះ មន្ត្រីពីមុនស្ថិតនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ។ ក្រោយ ពេលបញ្ចប់ពីមុខតំណែង មន្ត្រីសាមីត្រូវដាក់ពាក្យសុំចូលបំរើការងារក្នុងក្របខ័ណ្ឌដើមវិញ ដោយផ្តល់ជូនឋានន្តរស័ក្តិ-ថ្នាក់ និងប្រភេទកាំប្រៀវត្ស ដូចមានចែងក្នុងមាត្រា៥។

ក្នុងរយៈពេលបំពេញការងារក្នុងខុទ្ទកាល័យនេះ ត្រូវបានគិតអតីតភាពសំរាប់ឡើងឋានន្តរស័ក្តិ ឬ ថ្នាក់ និងអតីតភាពសំរាប់ទទួលសោធននិវត្តន៍។

**មាត្រា ១២** : មន្ត្រីបំរើការងារក្នុងខុទ្ទកាល័យរបស់ក្រសួងស្ថាប័ន ដែល ពីមុនពុំស្ថិតនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ក្រសួង ស្ថាប័នសាមី ត្រូវផ្តល់ប្រៀវត្សជូនជាមន្ត្រីជាប់កិច្ចសន្យា។ ទឹកប្រាក់ នេះអាស្រ័យដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈជាអ្នកកំណត់។

**មាត្រា ១៣** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីជនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**<u>កន្លែងទទួលៈ</u>**

- **ខុទ្ទកាល័យព្រះមហាក្សត្រ**
- **អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
- **អគ្គលេខាធិការដ្ឋានរដ្ឋសភា**
- **ក្រសួងព្រះបរមរាជវាំង**
- **ខុទ្ទកាល័យនាយករដ្ឋមន្ត្រី**
- **អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**
- **ដូចមាត្រា១៤**
- **រាជកិច្ច**
- **ឯកសារ កាលប្បវត្តិ**